HONEYCOMB 3/1 (January 2002): 47–55



# Human Rights and Responsibilities

## Approaching a Biblical Balance

*Rolf LEPELAAR*

## Introduction

Many people in today's world suffer greatly, often as the result of other people's action. The powerless often suffer at the hands of others. It is estimated that fifteen million children under the age of five die each year because they don't have enough food, water and medical care; and many of those who do survive are exploited by child labor and child prostitution. Untold numbers of street children are abused or killed by the local police. Millions of refugees and asylum seekers exist under inhumane conditions. The last one hundred years are full of events showing man's inhumanity to man. In the two world wars, approximately sixty million people were killed. Masses have died under their own leaders in Russia, Cambodia, Uganda, and China, as well as many Latin American countries.

How should people respond to facts such as these? In the last century there has been an increasing awareness and promotion of human rights. The concept of human rights is not new. It was already proclaimed in the Bible thousands of years ago. The British, French and American revolutions attempted to protect human dignity and people from abuse at the hands of the leaders and those with power. However after two world wars in the twentieth century it was decided

that more needed to be done to protect peace and human rights. Eglantyne Jebb, who had a Christian faith, witnessed the suffering of children in the First World War and played an important role in drafting the 1924 *Declaration of the Rights of the Child.* World War Two resulted in the organization of the United Nations in 1945 and the issuing of the *International Bill of Human Rights* in 1948.

Proponents of human rights have many different claims. First, human rights proponents from a western individualistic background proclaimed rights of the individual such as the right to life; the right to freedom of thought, opinion, conscience and religion; the right to participate in free and frequent elections; the right to equality; the right to privacy and to fairness before the law; and the prohibition of torture, slavery, and arbitrary arrests. Proponents of a more socialist background emphasized the right to work and fair pay, the right to leisure, and the right to form trade unions. Other rights proclaimed by many from different persuasions include the right to education, to proper medical treatment, and to social security.

Yet despite the advances of the human rights movement over the past fifty years there is still a massive amount of suffering and abuse of people. What should be the Christian's approach to these issues? Is proclamation of human rights the correct approach? Should we agree completely with everything that is proclaimed by advocates of human rights? Has the human rights movement gone beyond what is appropriate? This article will seek to show that Christians should be concerned with human rights, although we should make some corrections. For example, we cannot agree with some of the rights that are proclaimed, and we should have a correct balance between *human rights* and *human responsibility.* Moreover, the Bible also stresses God's right to rule over us. In order to clarify our thinking it would help to develop a biblical worldview, to understand the world through the teaching of the Bible.

## Biblical worldview

Genesis chapters one and two teach us that God created and sovereignly rules over everything. He created men and women in his image and spoke to them in a relational way. He instructed them in

the form of commands. They should "Be fruitful and increase in number; fill the earth and subdue it. Rule over the fish of the sea and the birds of the air and over every living creature that moves on the ground."[1] God also commands the man to take care of the garden.[2] These few truths gleaned from these chapters already have a great deal to teach us about the issue at hand. God created us with three kinds of relationships.

1. First with God. We were created to relate to God, to love him,[3] to obey him, to worship him, etc.
2. We were also created to relate to ourselves and fellow mankind. We are to love mankind.[4]
3. With nature. Our role is to fill the earth, subdue it, enjoy its fruits, and take care of it.[5]

In all these relationships God has bestowed on us *human responsibility*. We have the *responsibility* to love and obey God, the *responsibility* to love our neighbor, the *responsibility* to rule over and to take care of the earth. Moreover these truths tell of *God's rights* to rule over us. God has the right to command us, the right to give, the right to take away and the right to judge.[6] The final judgment is a great proclamation of these truths. Together with *responsibility* comes *accountability*. God's act of judgment over all mankind proclaims God's right to rule over us and our *accountability* for that which he has made us *responsible*. Therefore throughout the Bible there is a great emphasis on *human responsibility*.

At the same time the Bible also gives a true foundation for *human rights*. The fact that God made us in his image also gives mankind great dignity or value. Murder is a great evil because it is killing someone in the image of God.[7] The human rights tradition has

---

[1]Gen 1:26.
[2]Gen 2:15.
[3]Matt 22:37.
[4]Matt 22:38.
[5]Gen 1:28ff, 2:15.
[6]See Job 33:4, Ps 68:35; Matt 20:1–16; Ps 9:8.
[7]Gen 9:6.

tried to base human rights on human dignity or value. We see from the Bible that as man is created in the image of God he has that value to establish human rights. One problem for many in the human rights tradition of the twentieth century is that they came from a worldview that said man was not in the image of God but we are just the result of meaningless, purposeless chemical reactions in the past. If that is true then why should humans have any worth? Why should a human have any more rights than a dog or a rock? The biblical teaching that God creates us in his image gives a foundation for human dignity and human rights. The foundation for human rights is creation. Human beings never acquired them nor has any government or any other authority bestowed them. Occasionally governments and authorities simply recognize the dignity and rights that God has already bestowed (although they may not attribute them to God).

## Biblical teaching on defending human rights

There are a few passages that deal specifically with the issue of human rights.[8] When we read through these we see God has particular concern to defend the cause of the powerless. Human history shows that those with power take advantage of those without it. Hence the rich take advantage of the poor. Adults take advantage of children. There is often much injustice. God is a God of justice who is concerned for his whole creation. Therefore this injustice is displeasing to him and it is godly to defend the rights of the poor, the oppressed, the powerless. Romans 13 teaches that God established governments and authorities to promote law and order, to promote righteousness and justice. Therefore Christians should be concerned that those in authority will indeed promote these and not use their power to oppress the poor and make unjust laws.

---

[8]Ps 82:1–4, Prov 22:22–23; 31:8–9, Ecc.5:8–10; Is.10:1–4; Jer 5:26–29.

## Weaknesses in the human rights movement

Despite the fact that God is concerned with human rights as we have seen above, there are a number of concerns that Christians must have with the human rights movement. Below are listed a few such concerns.

**The abuse of the term "human rights"**

Consider the following two cases.

**a.** In some countries the issue of abortion is very much debated. Those who defend the act of abortion say that women have the right to choose, which means the right to kill their unborn child if that is their choice. What should we Christians believe regarding this? Does anyone have this right? Are we infringing on women's rights if we say they do not have the right to do this? If so, is it wrong to infringe on their rights? It is helpful to remember the biblical worldview that we learned above. God has the right to command us what to do. We do not have the right to rebel against God, but rather God has given us the responsibility to obey him. If God has not given women the right to kill their unborn child then they do not have that right. Christians should defend the rights of unborn babies in the image of God.

The debate regarding abortion and birth control can be quite complicated. What do we do in the situation where the baby is causing great danger to the mother's life? It is beyond the scope of this article to go into depth on this issue. However, whatever stance we make the purpose of the illustration still stands. All Christians should agree that when we approach this issue we should do so within the framework of human responsibility before God, not just the rights of the individual. Even if we are to talk of rights, we must not only think of the woman's rights but also the rights of the unborn child. A woman with child is two human beings, not one. We saw that God defends the cause of the helpless. Who is as helpless as an unborn child who is not seen and whose cry is not heard?

**b.** Another human right often proclaimed is the right to freedom of religion. Suppose that you evangelize someone but they respond they have a right to follow their own religion. How would you

respond? In some ways it is correct to say freedom of religion is a human right. Every human has the right to follow his conscience with regard to religion without being persecuted or being forced to recant or follow another religion. Each person has the right to make his or her own decision.

But in another sense to say that each person has the right to follow his own religion is misleading. Again we should introduce the biblical concept of *human responsibility*. Choice of religion is not only a *human right*, it is a *human responsibility*. As such we will be held accountable before God for the choice we make. If we choose idols we are guilty before God. If we choose the true God as revealed in the Bible we will be blessed by God. A great example of this is found in Joshua 24:14–24. (Read through several times.) Joshua was the leader of the people and therefore had authority over them. Yet despite having this authority he did not force them to follow God. He exhorted them to serve the true God but also told them that it was their choice. He warned them that they are accountable for their decision so if they follow idols they will come under God's judgment. Likewise, we cannot force people to become Christians. Yet it is our *responsibility* to witness about the true God and what he has done through his son Jesus, and it is their *responsibility* to respond with repentance and faith.

**The danger of proclaiming human rights without reference to God**

The examples in point number one above show the danger of proclaiming human rights without considering God's revealed will. Some in the human rights tradition believe there is no authority above man who commands us what to do and believe. If this is true then who can decide what is right and what is wrong? Who can decide what truly constitutes human rights? With no authority above us, the rights proclaimed will mirror the values of the people that proclaim them. Of course the clear danger here is that the values of these people may be misguided with no higher authority to challenge their assumptions. Christians know that our Creator has spoken authoritatively in the Bible and we must submit to his standards. His word is the lamp to our feet that can prevent us from walking into the darkness of moral mayhem.

**The uselessness of proclaiming *human rights* without fulfilling *human responsibility***

Let us consider the issue of education. Many proclaim that each child, male or female has a right to education. This is indeed true and very important. However, education is not just a right, it is a responsibility. It is the responsibility of the government to adequately fund education, and the responsibility of teachers *and* parents to teach the child and encourage him to learn. It is also the responsibility of the child to use his God-given mind as he applies it to learning. If there is an occasional speech proclaiming the right to education, but people do not fulfil their responsibility, then no improvement will be made. However, if proclaiming the right to education leads to people fulfilling their responsibility then progress has been made thanks partly to the proclamation of human rights.

**The danger of proclaiming human rights when the appropriate approach is human responsibility**

If you look again at the passages from the Bible listed above dealing with human rights you can see that it teaches us that we should defend the rights of *others*. It does not call us to defend our own rights, indeed the Christian is sometimes called upon to forgo his own rights.[9] Both noted passages deal with the issue of love. The two greatest commandments are to love God and love your neighbor. In loving others we must think of *our responsibility* to them. In loving others sometimes we must defend *their rights* and forgo our own. In relationships this can be very important.

Consider the most intimate relationship between people: marriage. Let us look at Paul's advice to husbands and wives in Ephesians 5:21–31 (read through). Paul does not tell husbands nor wives to defend their own rights. He does not instruct wives to tell their husbands to fulfil their responsibility, nor the husband to tell his wife to fulfil hers. (This does not mean a husband or wife cannot rebuke each other). Paul's advice to a married couple is that each party makes sure he or she is fulfilling his responsibility to his partner. This is very sound

---

[9]E.g., see Matt 5:38–48; 1 Cor 8:1–9:23.

advice. It will be beneficial for a marriage if each party strives to be faithful in his or her responsibility to his marriage partner, rather than just thinking about his own rights.

When we consider another relationship within the home, that between the parents and the children we can again see the danger of proclaiming *human rights* over against *human responsibility*. The U.N. Convention on the Rights of the Child has been involved in promoting children's rights. Some children's rights do need to be defended; however, religious groups have expressed concern that the incorrect proclamation of children's rights will undermine the rights and responsibilities of parents to raise, teach, develop, and discipline their child. For example, a parent disciplining her child with a smack may be accused of infringing the child's rights. A parent giving religious instruction to his child may be considered to be infringing on the rights of the child to make his own choice. Christians should be wary of any future developments such as these.

**The nature of mankind**

We have seen that Christians should promote human rights. We hope that promoting human rights will improve this world. Yet at the same time we must not think that this is the ultimate solution to the problems people face. Many believe that people are essentially good in nature and therefore they are optimistic regarding the results from human activities such as proclaiming human rights. Christians should not suffer such a delusion. The Bible clearly teaches that people have a sinful nature and that we are incapable of saving ourselves not only from the penalty we receive due to our sins, but also the power of sin over us.[10] Human solutions will not fix the problems in this world. But God has acted in Jesus to save us from our sins. The solution to the problems in this world is the gospel. In the gospel God not only forgives us from our sins, but gives us new life to be obedient to him. This gives true hope for a better society. We also wait for the future world when all will be made perfect.

---

[10]See Rom 7:7–24; Eph 2:1–3; Jer 13:23; 17:9.

## Conclusion

In the face of much suffering in this world Christians should defend the rights of the poor, defenseless and oppressed. We should seek to reform governments, systems, laws, companies, etc., so that people will be treated fairly.

Yet Christians should also be cautious of the abuse of the term "human rights." Christians working with secular organizations should be careful to check that what they are hearing is consistent with the Bible.

When we check with the Bible we realize that it places much more emphasis on human responsibility before God. We should proclaim to the world that they are accountable to God for the responsibilities that he has given them within the three relationships that were outlined above. Nothing is hidden from him; he sees everything right down to inside our hearts. The whole world has rebelled against God and is therefore under his judgement. We are incapable through human solutions or human religion to solve this problem. Yet God has acted to save us through Jesus, particularly what he accomplished in his death and resurrection. In the gospel God calls people to repent of their wrongdoing and believe in Jesus. This will not only bring personal salvation but true transformation of society.

## Sources

*Holy Bible, New International Version* (Grand Rapids: Zondervan, 1984).

Lorenzen, Thorward. "Christian Faith and Human Rights." *Evangelical Review of Theology* 24/1 (2000).

Stephenson, Paul. "Children's Rights: Has Anyone got it Right?" *Effective Service in a Broken World, Cutting Edge 2001 Conference Papers* (Council of International Children's Ministries).

Stott, John. *Authentic Christianity* (Leicester: IVP, 1996).

________. *New Issues Facing Christians Today* (London: Marshall Pickering, 1999).

សំណុំទឹកឃ្មុំ ៣/១ (មករា ២០០២): ៥៦-៧១



# សិទ្ធិមនុស្ស និងការទទួលខុសត្រូវ

## ការដោះស្រាយតាមគំរូនៅក្នុងព្រះគម្ពីរ ដែលមានតុល្យភាព

*លោក រ៉ហ្វ ឡាប៉ាឡា*

## សេចក្តីផ្តើម

មានមនុស្សជាច្រើននៅក្នុងលោកយើងសព្វថ្ងៃនេះស្ថិតនៅក្នុងការឈឺចាប់យ៉ាងខ្លាំងសម្បើម ជារឿយៗបណ្តាលមកពីសកម្មភាពរបស់មនុស្សដទៃ ។ អ្នកដែលគ្មានអំណាចតែងតែទទួលរងឈឺចាប់ក្រោមដៃរបស់អ្នកដទៃទៀត ។ គេប៉ាន់ប្រមាណឃើញថា មានក្មេងអាយុក្រោម៥ឆ្នាំប្រមាណ ១៥ លាននាក់ស្លាប់ជារៀងរាល់ឆ្នាំ ដោយសារតែខ្វះចំណីអាហារ ទឹក និងសេវាថែទាំសុខភាព ហើយចំពោះក្មេងទាំងនោះភាគច្រើន ដែលបានរួចជីវិតពីសេចក្តីស្លាប់ដូចបានពោលខាងលើត្រូវរងនូវការកេងប្រវ័ញ្ចផ្នែកផ្លូវភេទ និងបង្ខំឲ្យធ្វើការធ្ងន់ ។ ចំនួនក្មេងអនាថាដែលគេមិនប្រាប់ឲ្យយើងដឹងនោះ នគរបាលនៅតាមមូលដ្ឋានទាំងនោះប្រើអំណាចរំលោភឬសម្លាប់ ។ មានជនភៀសខ្លួន និងជនសុំសិទ្ធិជ្រកកោនរាប់លាននាក់កំពុងស្ថិតនៅក្រោមស្ថានភាពអមនុស្សធម៌ ។ នៅក្នុងរយៈពេល ១០០ឆ្នាំចុងក្រោយនេះ មានព្រឹត្តិការណ៍ជាច្រើនដែលបង្ហាញឲ្យឃើញភាពអមនុស្សធម៌របស់មនុស្ស ដែលមនុស្សបានធ្វើចំពោះមនុស្ស ។ នៅក្នុង

អំឡុងពេលសង្គ្រាមលោកទាំងពីរលើក មានមនុស្សស្លាប់ប្រហែល ៦០ លាននាក់ ។ មានមនុស្សយ៉ាងច្រើនសន្ធឹក ដែលបានស្លាប់នៅក្រោមកណ្ដាប់ដៃនៃអ្នកដឹកនាំរបស់គេផ្ទាល់នៅក្នុងប្រទេស រុស្ស៊ី កម្ពុជា យូហ្គាន់ដា និងប្រទេសចិន ដូចគ្នាដែរនៅក្នុងបណ្ដាប្រទេសជាច្រើននៅក្នុងអាមេរិកឡាទីន ។

តើមនុស្សត្រូវឆ្លើយតបទៅនឹងព្រឹត្តិការណ៍ទាំងនេះ ដោយរបៀបណា? នៅក្នុងសតវត្សចុងក្រោយនេះ មានការកើតឡើងនៃការយល់ដឹង និងលើកស្ទួយផ្នែកសិទ្ធិមនុស្ស ។ ផ្នត់គំនិតដែលគិតពីសិទ្ធិមនុស្សនោះមិនមែនជារឿងថ្មីឡើយ ។ គឺមានប្រកាសប្រាប់នៅក្នុងព្រះគម្ពីររាប់ពាន់ឆ្នាំរួចទៅហើយ ។ ការធ្វើបដិវត្តន៍របស់អង់គ្លេស បារាំង និង អាមេរិក ប៉ុនប៉ងដើម្បីការពារភាពថ្លៃថ្នូររបស់មនុស្ស និងការពារមនុស្សមិនឲ្យគេរងនូវការរំលោភសិទ្ធិនៅក្រោមកណ្ដាប់ដៃនៃពួកអ្នកដឹកនាំ និងអ្នកមានអំណាចទាំងឡាយនោះ ។ ទោះជាយ៉ាងណាក៏ដោយ បន្ទាប់ពីសង្គ្រាមលោកទាំងពីរលើកចប់នៅក្នុងសតវត្សទី ២០ គេបានសម្រេចចិត្តថា ខំធ្វើឲ្យបានសម្រេចថែមទៀតនោះ គឺការពារឲ្យមានសន្តិភាព និងសិទ្ធិមនុស្ស ។ អិកឡានតែន៍ ចេប ដែលជាអ្នកជឿព្រះបានឃើញផ្ទាល់នឹងភ្នែក ចំពោះការរងឈឺចាប់របស់កុមារ នៅក្នុងសង្គ្រាមលោកលើកទី១ និងមានតួនាទីសំខាន់នៅក្នុងសេចក្ដីព្រាងច្បាប់នៅឆ្នាំ ១៩២៤ ស្ដីពីការប្រកាសច្បាប់សិទ្ធិកុមារ ។ សង្គ្រាមលោកលើកទី២ ជាហេតុនាំឲ្យគេបង្កើតអង្គការសហប្រជាជាតិនៅក្នុងឆ្នាំ ១៩៤៥ និងការប្រកាសចេញច្បាប់អន្តរជាតិនៃច្បាប់សិទ្ធិមនុស្សនៅក្នុងឆ្នាំ ១៩៤៨ ។ ពួកអ្នកគាំទ្រសិទ្ធិមនុស្សមានការអះអាងផ្សេងៗជាច្រើន ។ ទីមួយ ពួកអ្នកគាំទ្រសិទ្ធិមនុស្សដែលមកពីភូមិភាគបស្ចិម មានសាវតាជាអ្នកប្រកាន់ភាពឯកត្តបុគ្គលបានប្រកាសអះអាងពីសិទ្ធិឯកត្តបុគ្គល ដូចជាសិទ្ធិនៃការរស់នៅ

សិទ្ធិសេរីភាពនៃការគិត ការបញ្ចេញយោបល់ មនសិការ និង សាសនា សិទ្ធិនៅក្នុងការចូលរួមក្នុងការបោះឆ្នោតដោយសេរី សិទ្ធិស្មើភាព (សមភាព) សិទ្ធិរក្សាភាពជាឯកជន និងទទួលនូវភាពយុត្តិធម៌នៅចំពោះមុខច្បាប់ និងមាន សិទ្ធិនៃការហាមប្រាមចំពោះការធ្វើទារុណកម្ម ទាសភាព និង ការប្រើអំណាច រំលោភបំពាន ។ ពួកអ្នកគាំទ្រដែលមានសាវតាលំអៀងទៅរកបែបអ្នកសង្គម និយមបានសង្កត់ធ្ងន់លើសិទ្ធិការងារ និងការបង់ប្រាក់ខែត្រឹមត្រូវ សិទ្ធិក្នុងការ ឈប់សម្រាកកាយ និងសិទ្ធិក្នុងការបង្កើតសហជីព ។ សិទ្ធិផ្សេងទៀតដែល បានអះអាងដោយមនុស្សជាច្រើនទៀត មកពីជំនឿផ្សេងៗ រួមទាំងសិទ្ធិក្នុង ការអប់រំ សិទ្ធិក្នុងការទទួលការព្យាបាលត្រឹមត្រូវ និង សិទ្ធិក្នុងសន្តិសុខ គ្រប់គ្រាន់នៅក្នុងសង្គម ។

ទោះជាយ៉ាងណាក៏ដោយសន្ធុះនៃចលនាគាំទ្រសិទ្ធិមនុស្សកាលពី ប៉ុន្មាន ៥០ ឆ្នាំកន្លងមកនេះ នៅតែមានការទទួលរងនូវការឈឺចាប់ និង ការរំលោភសិទ្ធិមនុស្សយ៉ាងសម្បើម និងចំនួនច្រើនធំធេងនៅឡើយ ។ តើអ្វីទៅដែលជាវិធីសាស្ត្ររបស់គ្រីស្ទបរិស័ទ ដើម្បីដោះស្រាយរឿងនេះ? តើការប្រកាសពីសិទ្ធិមនុស្សគឺជាវិធីត្រឹមត្រូវឬទេ? តើយើងយល់ស្រប ទាំងស្រុងលើអ្វីដែលពួកអ្នកគាំទ្រសិទ្ធិមនុស្សបានប្រកាសឬទេ? តើចលនា គាំទ្រសិទ្ធិមនុស្សជ្រុលហួសពីអ្វីដែលសមរម្យឬ? អត្ថបទនេះនឹងស្វែងរក នូវការបង្ហាញថា តើគ្រីស្ទបរិស័ទគួរចាប់អារម្មណ៍ចំពោះសិទ្ធិមនុស្ស ទោះបី ជាយើងត្រូវធ្វើការកែតម្រូវខ្លះៗនោះក៏ដោយ ។ ឧទាហរណ៍ យើងមិនយល់ ស្របតាមសិទ្ធិដែលគេបានប្រកាសនោះ ហើយយើងគួរកែតម្រូវតុល្យភាព រវាង *សិទ្ធិមនុស្ស* និង *ការទទួលខុសត្រូវ របស់មនុស្ស* ។ លើសពីនោះ ទៅទៀត ព្រះគម្ពីរក៏បានបញ្ជាក់ផងដែរ ពីសិទ្ធិរបស់ព្រះជាម្ចាស់ក្នុងការ ដែលព្រះអង្គគ្រប់គ្រងពីលើយើងនោះ ។ ដើម្បីបញ្ជាក់ឲ្យបានច្បាស់អំពី ការគិតរបស់យើងនេះ យើងត្រូវពឹងលើគតិលោក ដែលយកគំរូតាមព្រះគម្ពីរ

ដើម្បីស្វែងយល់អំពីប្រព័ន្ធគ្រប់គ្រងរបស់ពិភពលោកនេះ តាមរយៈសេចក្តីបង្រៀននៅក្នុងព្រះគម្ពីរ ។

## គតិលោកតាមបែបព្រះគម្ពីរ

លោកុប្បត្តិជំពូកមួយ និងជំពូកពីរបង្រៀនយើងថា ព្រះជាម្ចាស់បានបង្កើតរបស់សព្វសារពើ និងព្រះអង្គគ្រប់គ្រងទាំងអស់ ។ ព្រះអង្គបានបង្កើតបុរសនិងស្រីនៅក្នុងរូបអង្គទ្រង់ ហើយព្រះអង្គបានមានព្រះបន្ទូលមកកាន់ពួកគេតាមរបៀបមួយដែលមានទំនាក់ទំនងដ៏ល្អ ។ ព្រះអង្គបានបង្រៀនដល់ពួកគេតាមបែបមួយជារបៀបបង្គាប់បញ្ជា ។ គឺគេ "ត្រូវបង្កើតកូនពូនជាចៅ ហើយចំរើនឡើងដើម្បីបំពេញផែនដី និងគ្រប់គ្រងលើផែនដីនោះទៀតផង ។ គ្រប់គ្រងលើត្រីសមុទ្រ សត្វស្លាបនៅលើអាកាស ព្រមទាំងសត្វគ្រប់ប្រភេទទាំងអស់ដែលនៅលើដី"[១] ។ ព្រះជាម្ចាស់បានបញ្ជាឲ្យមនុស្សមើលថែសួន ។[២] សេចក្តីពិតដែលប្រមូលបានពីជំពូកទាំងនេះ គឺមានចំណែកយ៉ាងធំ ដើម្បីបង្រៀនយើងចំពោះបញ្ហានៅចំពោះមុខ ។ ព្រះជាម្ចាស់បានបង្កើតយើងមកឲ្យមានទំនាក់ទំនងបីយ៉ាង ។

១. ទីមួយជាមួយព្រះជាម្ចាស់ ។ ព្រះជាម្ចាស់បង្កើតយើងមកដើម្បីធ្វើការប្រកបទាក់ទងជាមួយព្រះអង្គ ស្រឡាញ់ព្រះអង្គ[៣] ឲ្យស្តាប់បង្គាប់ព្រះអង្គ ថ្វាយបង្គំព្រះអង្គ ។ល។

២. ព្រះជាម្ចាស់ក៏បង្កើតយើងមក ដើម្បីឲ្យយើងប្រកបទាក់ទងនឹងខ្លួនយើងផ្ទាល់ និងមនុស្សដូចគ្នា ។ យើងត្រូវស្រឡាញ់

---

[១] *លោកុ. ១:២៦*

[២] *លោកុ. ២:១៥*

[៣] *ម៉ាថាយ ២២:៣៧*

មនុស្សលោក ។[៤]

៣. ទំនាក់ទំនងជាមួយធម្មជាតិ ។ តួនាទីរបស់យើងត្រូវបង្កើតកូនពូនជាចៅនៅពេញពាសនៅលើផែនដី គ្រប់គ្រងផែនដី សប្បាយរីករាយជាមួយនិងផលផ្លែរបស់ផែនដី និងមើលថែផែនដីឲ្យបានល្អ ។[៥]

ចំពោះទំនាក់ទំនងទាំងអស់នេះព្រះជាម្ចាស់បានប្រទានមកឲ្យយើង *ផ្នែកទទួលខុសត្រូវរបស់មនុស្ស* ។ យើងមាន*ការទទួលខុសត្រូវ*ក្នុងការស្រឡាញ់ និងស្ដាប់បង្គាប់ព្រះជាម្ចាស់ មាន*ការទទួលខុសត្រូវ*ក្នុងការស្រឡាញ់អ្នកជិតខាងរបស់យើង មាន*ការទទួលខុសត្រូវ*ត្រួតត្រា និងមើលថែផែនដី ។ លើសពីនេះទៅទៀត សេចក្ដីពិតទាំងនេះប្រាប់យើងពី*សិទ្ធិរបស់ព្រះជាម្ចាស់* ក្នុងការដែលព្រះអង្គគ្រប់គ្រងលើយើង ។ ព្រះជាម្ចាស់មានសិទ្ធិបញ្ជាយើង មានសិទ្ធិក្នុងការប្រទានឲ្យ មានសិទ្ធិក្នុងដកយកវិញ និងមានសិទ្ធិក្នុងការជំនុំជំរះកាត់ក្ដី ។[៦] សេចក្ដីជំនុំជំរះនៅថ្ងៃចុងក្រោយគឺជាការប្រកាសដ៏ធំសម្បើមពីសេចក្ដីពិតទាំងនេះ ។ ការទទួលខុសត្រូវជាមួយគ្នាក៏មានការព្រមចុះចូលទទួលខុសត្រូវនោះមកដែរ ។ ព្រះជាម្ចាស់ជំនុំជំរះមនុស្សលោកទាំងអស់ ការនោះប្រកាសពីសិទ្ធិរបស់ព្រះជាម្ចាស់ដែលព្រះអង្គគ្រប់គ្រងលើយើង និងទាមទារនូវការទទួលខុសត្រូវដែលព្រះអង្គប្រគល់មកឲ្យយើងទទួលខុសត្រូវនោះឯង ។ ហេតុដូច្នេះហើយនៅក្នុងព្រះគម្ពីរទាំងមូលមានចែងសង្កត់ធ្ងន់ លើការទទួលខុសត្រូវរបស់មនុស្ស ។

នៅក្នុងពេលជាមួយគ្នានេះដែរ ព្រះគម្ពីរក៏បានផ្ដល់នូវគ្រឹះដ៏ពិតប្រាកដ

---

[៤] *ម៉ាថាយ ២២:៣៨*

[៥] *លោកុ. ១:២៨, ២:១៥*

[៦] *សូមមើលយ៉ូប ៣៣:៤, ទំនុក. ៦៨:៣៥*

ចំពោះសិទ្ធិមនុស្ស ។ ហេតុដែលព្រះជាម្ចាស់បង្កើតយើងមកក្នុងរូបអង្គទ្រង់នោះ គឺផ្តល់នូវភាពថ្លៃថ្នូរ និងតម្លៃចំពោះមនុស្សលោក ។ ការសម្លាប់គឺជាអំពើអាក្រក់បំផុត ពីព្រោះគឺជាការសម្លាប់អ្នកដែលព្រះជាម្ចាស់បង្កើតគេមកនៅក្នុងរូបអង្គទ្រង់នោះឯង[៧] ។ ទម្លាប់នៃការគាំទ្រសិទ្ធិមនុស្សនោះបានព្យាយាមពឹងផ្អែកលើភាពថ្លៃថ្នូរ ឬ លើតម្លៃរបស់មនុស្ស ។ យើងបានដឹងពីព្រះគម្ពីរហើយ ដោយហេតុថាមនុស្សព្រះជាម្ចាស់បង្កើតមកក្នុងរូបអង្គទ្រង់នោះទើបមនុស្សមានតម្លៃក្នុងការបង្កើតនូវការគាំទ្រសិទ្ធមនុស្ស ។ មានបញ្ហាមួយនៅក្នុងទំលាប់នៃការគាំទ្រសិទ្ធិមនុស្សនៅក្នុងសតវត្សទី២០នេះ គឺចេញមកពីគតិលោកមួយបែប ដែលនិយាយថាមនុស្សមិនមែនបានបង្កើតមកនៅក្នុងរូបអង្គទ្រង់នោះឡើយ ប៉ុន្តែមនុស្សគ្រាន់ជាការកើតឡើងពីប្រតិកម្មនៃសារធាតុគីមីដោយចៃដន្យកាលពីដើមតែប៉ុណ្ណោះ គឺគ្មានន័យ និងគ្មានគោលដៅអ្វីទាំងអស់ ។ បើសិនការនោះជាការពិតមែន អ៊ីចឹងហេតុអ្វីបានជាមនុស្សគួរមានតម្លៃនោះ? ហេតុអ្វីបានជាមនុស្សត្រូវមានសិទ្ធិច្រើនជាងឆ្កែ ឬជុំថ្ម? សេចក្តីបង្រៀននៅក្នុងព្រះគម្ពីរឲ្យយើងបានដឹងថាព្រះជាម្ចាស់បានបង្កើតយើងមកនៅក្នុងរូបអង្គទ្រង់ គឺបានផ្តល់នូវគ្រឹះសំខាន់ចំពោះភាពថ្លៃថ្នូរ និងសិទ្ធិរបស់មនុស្ស ។ គ្រឹះសំខាន់សំរាប់សិទ្ធិមនុស្សនោះ គឺទាក់ទងទៅនឹងការកកើត ។ មនុស្សមិនចាំបាច់ត្រូវការសិទ្ធិទាំងអស់នោះ ឬត្រូវការឲ្យរដ្ឋាភិបាលណាមួយ ឬសិទ្ធអំណាចណាមួយផ្តល់សិទ្ធិនោះឲ្យឡើយ ព្រោះមនុស្សមានសិទ្ធិនោះរួចទៅហើយ ។ យូរៗម្តងរដ្ឋាភិបាលនានា និងសិទ្ធិអំណាចនៃអាជ្ញាធរនានា ក៏ព្រមទទួលស្គាល់នូវភាពថ្លៃថ្នូរ និងសិទ្ធិដែលព្រះជាម្ចាស់បានផ្តល់ឲ្យមកមនុស្សរួចហើយនោះខ្លះដែរ (ទោះបីជាគេមិនបានឲ្យ តម្លៃចំពោះការនោះថ្វាយទៅព្រះជាម្ចាស់ក៏ដោយចុះ) ។

---

[៧] *លោកុ.៩:៦*

## សេចក្តីបង្រៀនរបស់ព្រះគម្ពីរស្តីពីការការពារសិទ្ធិមនុស្ស

មានអត្ថបទគម្ពីរមួយចំនួនដែលទាក់ទងជាពិសេសជាមួយសិទ្ធិមនុស្ស ។[៨] នៅពេលដែលយើងបានអានខគម្ពីរទាំងនេះ យើងឃើញថាព្រះជាម្ចាស់យកព្រះហឫទ័យទុកដាក់ដល់អ្នកដែលទន់ខ្សោយ ។ តាមប្រវត្តិសាស្ត្រមនុស្សជាតិបង្ហាញថា អស់អ្នកដែលមានអំណាចបានទទួលនូវការកេងយកប្រយោជន៍ពីអ្នកដែលគ្មានអំណាច ។ ហេតុនេះទើបបានជាពួកអ្នកមានកេងយកប្រយោជន៍ពួកអ្នកក្រ ។ ពួកមនុស្សពេញវ័យកេងយកចំណេញចំពោះកុមារ ជារឿយៗតែងមានភាពអយុត្តិធម៌ជាច្រើន ។ ព្រះជាម្ចាស់គឺជាព្រះដែលប្រកបទៅដោយសេចក្តីយុត្តិធម៌ ព្រះអង្គមានព្រះហឫទ័យទុកដាក់ចំពោះរបស់សព្វសារពើដែលព្រះអង្គបានបង្កើតមកទាំងអស់ ។ ហេតុដូច្នេះហើយភាពអយុត្តិធម៌នេះ ធ្វើឲ្យព្រះអង្គមិនសព្វព្រះហឫទ័យឡើយ ហើយជាការត្រឹមត្រូវណាស់ដែលយើងត្រូវការពារអ្នកក្រីក្រ អ្នកដែលគេជិះជាន់ អ្នកទន់ខ្សោយដែលគ្មានអំណាចនោះ ។ គម្ពីររ៉ូមជំពូក ១៣ បានបង្រៀនយើងឲ្យដឹងថា ព្រះជាម្ចាស់ជាអ្នកបង្កើតរដ្ឋាភិបាល និងអាជ្ញាធរ ដើម្បីឲ្យគេជាលើកកំពស់ផ្នែកផ្លូវច្បាប់ និងផ្នែកសណ្តាប់ធ្នាប់សង្គម ជួយលើកកំពស់សេចក្តីសុចរិត និងសេចក្តីយុត្តិធម៌ ។ ហេតុដូច្នេះហើយ គ្រីស្តបរិស័ទត្រូវតែយកចិត្តទុកដាក់ ចំពោះអាជ្ញាធរទាំងឡាយដែលនឹងជួយលើកកំពស់ការទាំងអស់នេះ និងមិនមែនប្រើអំណាចរបស់ខ្លួនទៅជិះជាន់សង្កត់សង្កិនចំពោះអ្នកទន់ខ្សោយក្រក្រី និងមិនមែនបង្កើតច្បាប់មិនយុត្តិធម៌សំរាប់ពួកគេនោះឡើយ ។

---

*[៨] ទំនុក. ៨២:១-៤, សុភាសិត ២២:២២-២៣; ៣១:៨-៩, សាស្តា ៥:៨-១០: អេសាយ ១០:១-៤; យេរេមា ៥:២៦-២៩*

## ចំណុចខ្សោយនៅក្នុងចលនាគាំទ្រសិទ្ធិមនុស្ស

ទោះបីជាព្រះជាម្ចាស់យកព្រះហឫទ័យទុកដាក់ ចំពោះសិទ្ធិមនុស្ស ក៏ដោយ ដូចដែលយើងបានឃើញនៅខាងលើនេះស្រាប់ មានការខ្វល់ខ្វាយ មួយចំនួនដែលគ្រីស្តបរិស័ទត្រូវតែមានចំណែកជាមួយចលនាគាំទ្រ សិទ្ធិមនុស្ស ។ មានបញ្ជីរាយប្រាប់ពីការខ្វល់ខ្វាយទាំងនោះដូចខាងក្រោម នេះគឺ:

ការប្រើពាក្យ "សិទ្ធិមនុស្ស" ច្រើនជ្រុល ។

ចូរពិចារណាមើលពីករណីពីរយ៉ាងដូចខាងក្រោមនេះ ។

ក. នៅប្រទេសខ្លះចំពោះបញ្ហាការពន្លូតកូន គឺជាពិភាក្សាតវ៉ាគ្នា យ៉ាងខ្លាំង។ ចំពោះអ្នកដែលគាំទ្រចំពោះការពន្លូតកូន និយាយថាស្ត្រី មានសិទ្ធិក្នុងការជ្រើសរើស ដែលមានន័យថាគេអាចមានសិទ្ធិក្នុងការសម្លាប់ កូននៅក្នុងផ្ទៃរបស់ខ្លួន បើសិនជាគេជ្រើសរើសធ្វើបែបនោះ ។ ទាក់ទងទៅ រឿងនេះ តើយើងជាគ្រីស្តបរិស័ទជឿដូចម្តេចដែរ? តើមនុស្សគ្រប់រូបមាន សិទ្ធិធ្វើបែបនេះមែនឬ? តើយើងកំពុងរំលោភសិទ្ធិរបស់ស្ត្រី បើសិន ជាយើងថាស្ត្រីមិនអាចមានសិទ្ធិក្នុងការធ្វើបែបនោះឡើយ? បើដូច្នោះមែន តើត្រឹមត្រូវដែរឬចំពោះការរំលោភសិទ្ធិរបស់ស្ត្រីនោះ? គឺជាការមួយដែល មានប្រយោជន៍ណាស់ដើម្បីដោះស្រាយបញ្ហានេះ គឺត្រូវយើងចងចាំ ពីគតិលោករបស់ព្រះគម្ពីរដែលយើងបានរៀនរួចមកហើយ ។ ព្រះជាម្ចាស់ មានសិទ្ធិក្នុងការបង្គាប់យើងឲ្យធ្វើអ្វីនោះ ។ យើងគ្មានសិទ្ធិក្នុងការបះបោរ ប្រឆាំងទាស់នឹងព្រះជាម្ចាស់ឡើយ តែព្រះជាម្ចាស់ទេដែលផ្តល់ឲ្យយើង មានការទទួលខុសត្រូវ ដើម្បីឲ្យយើងស្តាប់បង្គាប់ដល់ព្រះអង្គ ។ បើសិន ព្រះជាម្ចាស់មិនបានផ្តល់សិទ្ធិដល់ស្ត្រីឲ្យសម្លាប់កូនដែលនៅក្នុងផ្ទៃរបស់ខ្លួន ទេនោះ ស្ត្រីក៏គ្មានសិទ្ធិធ្វើបែបនោះដែរ ។ គ្រីស្តបរិស័ទត្រូវការពារសិទ្ធិ

ទារកមិនទាន់កើត ព្រោះគេក៏ជារូបអង្គព្រះជាម្ចាស់ដែរ ។

ការពិភាក្សាដេញដោលចំពោះបញ្ហាដែលទាក់ទងចំពោះការពន្លូតកូន និង ការប្រើថ្នាំពន្យារកំណើតអាចជាបញ្ហាស្មុគស្មាញមែនទែន ។ ចុះតើយើងត្រូវធ្វើអ្វីទៅ នៅក្នុងស្ថានភាពដែលទារកជាមូលហេតុគំរាមដល់អាយុជីវិតរបស់ម្តាយនោះ? រឿងនេះគឺវាហួសពីសមត្ថភាពដែលអត្ថបទនេះដោះស្រាយឲ្យស៊ីជម្រៅចំពោះបញ្ហានេះ ។ ទោះបីជាយ៉ាងក៏ដោយ ទោះជាយើងឈរលើជំហរបែបណានោះ គោលបំណងនៃការព្យាយាមបញ្ជាក់បង្ហាញនោះនៅតែដដែល ។ គ្រីស្តបរិស័ទទាំងអស់ត្រូវតែយល់ព្រមចំពោះរឿងនេះ នៅពេលដែលយើងទើបប្រទះចំពោះបញ្ហានេះ យើងត្រូវធ្វើការនេះនៅរង្វង់នៃការទទួលខុសត្រូវរបស់យើងជាមនុស្សនៅចំពោះព្រះជាម្ចាស់ មិនមែនត្រូវផ្អែកលើសិទ្ធិផ្ទាល់ខ្លួនរបស់យើងម្នាក់ៗនោះឡើយ។ ទោះបីជាយើងត្រូវនិយាយអំពីសិទ្ធិមនុស្សក៏ដោយ យើងមិនត្រូវគ្រាន់តែគិតពីសិទ្ធិរបស់ស្ត្រីនោះឡើយ តែត្រូវគិតពីសិទ្ធិរបស់ទារកដែលគេមិនទាន់កើតនោះផង ។ ស្ត្រីមានផ្ទៃពោះនោះមិនមែនជាមនុស្សតែម្នាក់នោះទេ គឺជាមនុស្សពីរនាក់ ។ យើងបានដឹងហើយថាព្រះជាម្ចាស់ការពារអ្នកដែលមិនអាចការពារខ្លួនឯងបាន ។ តើមានអ្នកណាទៀតដែលមិនអាចការពារខ្លួនឯងបាន ក្រៅពីទារកដែលនៅក្នុងផ្ទៃនោះដែលគេមើលមិនឃើញ និងយំមិនឮនោះ?

ខ. សិទ្ធិមនុស្សមួយបែបទៀត ដែលតែងតែអះអាងថា ជាសិទ្ធិសាសនា ។ ឧបមាថា លោកអ្នកផ្សាយដំណឹងល្អនរណាម្នាក់ ប៉ុន្តែគេឆ្លើយថាគេមានសិទ្ធិនឹងជឿតាមសាសនារបស់គេផ្ទាល់ដែរ ។ តើលោកអ្នកនឹងឆ្លើយតបយ៉ាងណា? តាមរបៀបខ្លះត្រឹមត្រូវ ហើយដែលអាចនិយាយពីសិទ្ធិសាសនានោះគឺជាសិទ្ធិមនុស្ស ។ មនុស្សគ្រប់រូបមានសិទ្ធិនឹងធ្វើតាមសម្បជញ្ញៈរបស់ខ្លួន ដែលទាក់ទងជាមួយនឹងសាសនាដោយគ្មានទទួល

នូវការបៀតបៀន ឬវាយដំបង្ខំឲ្យបោះបង់ជំនឿរបស់ខ្លួន ហើយទៅជឿតាមជំនឿសាសនាផ្សេងនោះឡើយ ។ មនុស្សមានសិទ្ធិក្នុងការសម្រេចចិត្តរបស់ខ្លួន ។

ប៉ុន្តែក្នុងន័យមួយទៀតនោះចង់និយាយថា មនុស្សម្នាក់ៗមានសិទ្ធិនឹងជឿតាមសាសនារបស់ខ្លួនផ្ទាល់គឺមិនមែននាំទៅរកផ្លូវខុស ។ យើងសូមលើកឡើងមកជំរាបជូនម្តងទៀតពី គោលគំនិតនៃការទទួលខុសត្រូវរបស់មនុស្ស ។ ជំរើសនៃការទទួលជឿលើសាសនានោះមិនមែនជាសិទ្ធិមនុស្សតែមួយនោះឡើយ គឺជាការទទួលខុសត្រូវរបស់មនុស្សដែរ ។ ដោយហេតុនោះ យើងនឹងត្រូវទទួលខុសត្រូវចំពោះព្រះជាម្ចាស់នូវអ្វីដែលយើងបានធ្វើការសម្រេចនោះ ។ បើសិនយើងជ្រើសរើសការថ្វាយបង្គំរូបព្រះនោះ យើងនឹងជាប់ពិរុទ្ធចំពោះព្រះជាម្ចាស់ហើយ ។ បើសិនយើងជ្រើសរើសយកព្រះពិតដើម្បីថ្វាយបង្គំ ដូចដែលគម្ពីរបានចែងនោះ យើងនឹងទទួលបានព្រះពរពីព្រះជាម្ចាស់ជាក់ជាមិនខាន ។ គំរូដ៏អស្ចារ្យអំពីការនេះយើងបានឃើញនៅក្នុងកណ្ឌគម្ពីរ យ៉ូស្វេ ២៤:១-២៤ ។ (សូមអានបួនប្រាំដង) ។ យ៉ូស្វេជាអ្នកដឹកនាំរបស់ពួកបណ្តាជន ហេតុដូច្នេះហើយបានជាគាត់មានសិទ្ធិអំណាចលើពួកគេ ។ ថ្វីដ្បិតតែគាត់មានសិទ្ធិអំណាចនេះក៏ដោយចុះ ក៏គាត់មិនបានប្រើអំណាចបង្ខំគេឲ្យជឿនិងដើរតាមព្រះជាម្ចាស់ដែរ ។ គាត់បានលើកទឹកចិត្តគេឲ្យគេបំរើព្រះពិត ប៉ុន្តែក៏បានប្រាប់គេដែរសូមឲ្យគេធ្វើការសម្រេចចិត្តដោយខ្លួនឯង ។ គាត់បានព្រមានគេថាពួកគេត្រូវតែទទួលខុសត្រូវនូវអ្វីដែលគេបានធ្វើការសម្រេចចិត្តនោះ បើសិនគេសម្រេចចិត្តថ្វាយបង្គំរូបព្រះ គេនឹងទទួលនូវសេចក្តីជំនុំជំរះពីព្រះជាម្ចាស់ ។ ដូចគ្នានេះដែរ យើងមិនអាចបង្ខំមនុស្សណាម្នាក់ឲ្យក្លាយជាគ្រីស្ទបរិស័ទឡើយ ។ តែគឺជាការទទួលខុសត្រូវរបស់យើងក្នុងការធ្វើបន្ទាល់អំពី ព្រះពិតហើយនិងប្រាប់គេនូវអ្វីដែលព្រះអង្គបានធ្វើតាមរយៈព្រះរាជបុត្រារបស់ព្រះអង្គ

គឺព្រះយេស៊ូនោះឯងហើយ គឺជាការទទួលខុសត្រូវរបស់គេ ចំពោះការឆ្លើយតបថាគេព្រមទទួល និងព្រមជឿឬយ៉ាងណានោះ។

## គ្រោះថ្នាក់ចំពោះការប្រកាសពីសិទ្ធិមនុស្ស ដោយគ្មានការនិយាយយោងទៅដល់ព្រះជាម្ចាស់

គំរូនៅក្នុងចំណុចលេខមួយខាងលើ បង្ហាញឲ្យឃើញពីគ្រោះថ្នាក់នៃការប្រកាសអំពីស្ដីពីសិទ្ធិមនុស្ស ដោយមិនបានគិតពីការបើកសម្ដែងនៃបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ។ ទំលាប់របស់អ្នកប្រកាន់ខ្ជាប់សិទ្ធិមនុស្សខ្លះ ជឿថាគ្មានសិទ្ធិអំណាចណាដែលខ្ពស់ជាងមនុស្សនោះឡើយដែលបង្គាប់យើងឲ្យធ្វើអ្វី និងជឿលើអ្វីនោះ ។ បើសិនការនោះពិតមែននោះ អ៊ីចឹងនរណាអាចសម្រេចថាអ្វីខុស និងអ្វីត្រូវ? តើនរណាអាចសម្រេចថាអ្វីជាគ្រឹះស្ថានពិតប្រាកដស្ដីពីសិទ្ធិមនុស្ស? ចំពោះការគ្មានសិទ្ធិអំណាចនៅពីលើយើងនោះ ការប្រកាសពីសិទ្ធិមនុស្សនឹងឆ្លុះបញ្ចាំងឲ្យឃើញពីមនុស្សដែលជាអ្នកប្រកាសនោះថាជាអ្នកមានតម្លៃ ។ ពិតប្រាកដណាស់ហើយ គ្រោះថ្នាក់កន្លែងនេះបង្ហាញយ៉ាងច្បាស់ពីតម្លៃនៃមនុស្សទាំងនេះ ដែលអាចធ្វើទៅមានការយល់ខុសដោយព្រោះគ្មានសិទ្ធិអំណាចណាខ្ពស់ជាងនេះមកជំរុញចំពោះការយល់ ដឹងរបស់គេនោះឯង ។ គ្រីស្ដបរិស័ទបានដឹងថា ព្រះអាទិកររបស់យើងបានមានបន្ទូលប្រកបដោយសិទ្ធិអំណាចនៅក្នុងព្រះគម្ពីរ ហើយយើងត្រូវចុះចូលចំពោះមាត្រដ្ឋានដ៏សំខាន់របស់ព្រះអាទិករនេះ ។ ព្រះបន្ទូលរបស់ព្រះអង្គជាចង្កៀងបំភ្លឺជើងរបស់យើង ដើម្បីការពារជើងរបស់យើងមិនឲ្យដើរចូលទៅក្នុងសេចក្ដីងងឹតនៃសីលធម៌ច្របូកច្របល់ គ្មានសណ្ដាប់ធ្នាប់ ។

## ការប្រកាសសិទ្ធិមនុស្សដែលឥតប្រយោជន៍ ដោយព្រោះការមិនបានបំពេញតួនាទីទទួលខុសត្រូវរបស់មនុស្ស

ចូរយើងពិចារណាស្តីពីការអប់រំ ។ មានមនុស្សជាច្រើន បានប្រកាសអះអាងថាកុមារ មិនថាប្រុស ឬស្រីនោះឡើយ គឺមានសិទ្ធិទទួលនូវការអប់រំដូចគ្នា ។ តាមពិតទៅការនេះពិតប្រាកដ ហើយសំខាន់ណាស់ទៀតផង ។ ទោះជាយ៉ាងណាក៏ដោយ ការអប់រំនោះមិនមែនគ្រាន់តែជាសិទ្ធិនោះប៉ុណ្ណោះទេ តែវាជាការទទួលខុសត្រូវ ។ គឺជាការទទួលខុសត្រូវរបស់រដ្ឋាភិបាលក្នុងការផ្តល់ថវិកាគ្រប់គ្រាន់ក្នុងវិស័យអប់រំ ជាការទទួលខុសត្រូវរបស់គ្រូបង្រៀន និងមាតាបិតាក្នុងការបង្រៀនកុមារ និងលើកទឹកចិត្តឲ្យគេខំរៀន ។ វាក៏ជាការទទួលខុសត្រូវរបស់កុមារដែរ ក្នុងការប្រើគំនិតដែលព្រះជាម្ចាស់ប្រទានឲ្យគេដោយយកគំនិតទៅរៀនសូត្រ ។ បើសិនជាការប្រកាសសិទ្ធិនៃការទទួលនូវការអប់រំយូរៗម្តង តែមនុស្សមិនបានបំពេញនូវការទទួលខុសត្រូវរបស់ខ្លួននោះ អ៊ីចឹងការនោះមិនអាចមានភាពប្រសើរឡើងបានទេ ។ ទោះជាយ៉ាងណាក៏ដោយ បើសិនការប្រកាសសិទ្ធិនូវការទទួលការអប់រំនោះនាំឲ្យមនុស្សបានសម្រេចនូវការទទួលខុសត្រូវរបស់ខ្លួន អ៊ីចឹងការរីកចំរើននោះនឹងអាចកើតមានឡើងមែន សូមអរគុណចំពោះការប្រកាសអំពីសិទ្ធិមនុស្សនោះឯង ។

## គ្រោះថ្នាក់នៃការប្រកាសសិទ្ធិមនុស្ស នៅពេលដែលយុទ្ធសាស្ត្រសង្គមនោះ គឺការទទួលខុសត្រូវរបស់មនុស្សនោះ តែបែរជាមិនប្រើ

បើសិនជាយើងមើលម្តងទៀតនូវអត្ថបទនៅក្នុងព្រះគម្ពីរ ដែលរាយក្នុងបញ្ជីដែលទាក់ទងទៅនឹងសិទ្ធិមនុស្សនៅខាងដើមនោះ លោកអ្នកអាច

មើលឃើញចំណុចទាំងនោះបង្រៀនយើងឲ្យដឹងថា យើងត្រូវការពារសិទ្ធិរបស់អ្នកដទៃ ។ ព្រះជាម្ចាស់មិនបានត្រាស់ហៅយើងមកឲ្យការពារសិទ្ធិរបស់ខ្លួនឯងឡើយ តែតាមពិតទៅ ជួនកាលព្រះជាម្ចាស់ត្រាស់ហៅគ្រីស្ដបរិស័ទឲ្យលះបង់សិទ្ធិរបស់ខ្លួនដែរ ។[៩] អត្ថបទគម្ពីរទាំងពីរដែលបានលើកឡើងនោះ និយាយពីសេចក្ដីស្រឡាញ់ ។ បញ្ញត្តិដ៏ធំសំខាន់ទាំងពីរនោះគឺត្រូវស្រឡាញ់ព្រះជាម្ចាស់និងអ្នកជិតខាងរបស់ខ្លួន។ ចំពោះការស្រឡាញ់អ្នកដទៃនោះ យើងត្រូវគិតពីការទទួលខុសត្រូវរបស់យើងចំពោះគេ ។ ចំពោះការស្រឡាញ់អ្នកដទៃ យើងជួនកាលត្រូវការពារសិទ្ធិរបស់គេ ហើយលះបង់សិទ្ធិរបស់យើងផ្ទាល់ ។ នៅក្នុងការធ្វើឲ្យមានទំនាក់ទំនងជិតស្និទ្ធនោះគឺជាការសំខាន់បំផុត ។

សូមពិចារណាពីទំនាក់ទំនងយ៉ាងជិតស្និទ្ធបំផុតរវាងមនុស្សនិងមនុស្សគឺៈ អាពាហ៍ពិពាហ៍ ។ សូមឲ្យយើងមើលទៅដំបូន្មានដែលលោកប៉ូលបានផ្ដល់ឲ្យប្ដីនិងប្រពន្ធនៅក្នុង អេភេសូរ ៥:២១-៣១ (សូមអានអត្ថបទគម្ពីរនោះ) ។ លោកប៉ូលមិនបានប្រាប់ប្ដី ឬប្រពន្ធឲ្យការពារសិទ្ធិរបស់ខ្លួននោះឡើយ ។ គាត់មិនបានបង្រៀនប្រពន្ធឲ្យប្រាប់ប្ដីឲ្យបំពេញតួនាទីទទួលខុសត្រូវរបស់ខ្លួនទេ ឬក៏មិនបានប្រាប់ប្ដីឲ្យទៅប្រាប់ប្រពន្ធឲ្យបំពេញតួនាទីរបស់ខ្លួនឡើយ ។ (ត្រង់នេះមិនមែនបានសេចក្ដីថា ប្ដីឬប្រពន្ធមិនអាចស្ដីបន្ទោសគ្នាបាននោះឡើយ) ។ សេចក្ដីទូន្មានរបស់លោកប៉ូលចំពោះអ្នកដែលមានប្ដីមានប្រពន្ធនោះគឺថា ម្នាក់ៗត្រូវដឹងច្បាស់ពីតួនាទីទទួលខុសត្រូវរបស់ខ្លួនដែលខ្លួនត្រូវបំពេញ ចំពោះដៃគូរបស់ខ្លួននោះ ។ នេះគឺជាដំបូន្មានមួយដ៏ប្រពៃបំផុត ។ ដំបូន្មាននេះនឹងផ្ដល់អត្ថប្រយោជន៍សំខាន់ចំពោះអ្នកដែលមានគូស្រករហើយ បើម្នាក់ៗព្យាយាមស្មោះត្រង់

---

*[៩] ឧទាហរណ៍ សូមមើលនៅក្នុងម៉ាថាយ ៥:៣៨-៤៨; ១កូរិន. ៨:១-៩:២៣។*

ចំពោះការទទួលខុសត្រូវរបស់ខ្លួនដោយគិតដល់ដៃគូរបស់ខ្លួន ជាជាងគិតអំពីសិទ្ធិរបស់ខ្លួនផ្ទាល់ ។

នៅពេលដែលយើងពិចារណាមើលទំនាក់ទំនងមួយទៀត នៅក្នុងផ្ទះ គឺរវាងឪពុកម្តាយនិងកូន យើងអាចឃើញពីគ្រោះថ្នាក់នៃការប្រកាសសិទ្ធិមនុស្សដែលប្រឆាំងនឹងការទទួលខុសត្រូវរបស់មនុស្ស ។ អង្គសមាជនៃអង្គការសហប្រជាជាតិស្តីពីសិទ្ធិមនុស្ស ដែលមានទាក់ទងទៅនឹងការលើកកំពស់ដល់សិទ្ធិកុមារ ។ សិទ្ធិកុមារត្រូវការជាចាំបាច់ដើម្បីការពារ ទោះបីយ៉ាងណាក៏ដោយក្រុមអ្នកកាន់សាសនា បានបង្ហាញពីការខ្វល់ខ្វាយដែលទាក់ទងនឹងការប្រកាសសិទ្ធិកុមារ នឹងធ្វើឲ្យសិទ្ធិ និងការទទួលខុសត្រូវរបស់ឪពុកម្តាយ ចំពោះបីបាច់ថែទាំកូន បង្រៀន អភិវឌ្ឍ ហើយប្រដៅតម្រង់កូនបែរជាចុះខ្សោយ ។ ឧទាហរណ៍ ឪពុកម្តាយប្រដៅកូនដោយវាយតប់នោះ ប្រហែលជាអាចចោទប្រកាន់ថារំលោភលើសិទ្ធិកុមារ ។ ចំពោះឪពុកម្តាយផ្តល់នូវការបង្រៀនដល់កូនចៅរបស់ខ្លួន តាមសាសនានោះ អាចទទួលនូវការពិចារណាពីអ្នកដទៃថា ជាការរំលោភលើសិទ្ធិកូនដែរ ដោយកូនមិនជ្រើសរើសតាមគំនិតរបស់ខ្លួនផ្ទាល់ ។ គ្រីស្តបរិស័ទត្រូវប្រុងប្រយ័ត្ន ចំពោះការកើតរឿងបែបនេះថ្ងៃអនាគត ។

## និស្ស័យរបស់មនុស្ស

យើងឃើញហើយថា គ្រីស្តបរិស័ទត្រូវលើកកំពស់សិទ្ធិមនុស្ស ។ យើងសង្ឃឹមថាការលើកកំពស់សិទ្ធិមនុស្សនឹងជួយពិភពលោកនេះមានភាពប្រសើរឡើង ។ តែនៅពេលជាមួយគ្នានេះដែរ យើងមិនត្រូវគិតថានេះជាដំណោះស្រាយតែមួយគត់ ចំពោះបញ្ហាទាំងឡាយដែលមនុស្សទាំងអស់កំពុងជួបប្រទះនូវបញ្ហានោះឡើយ ។ មានមនុស្សជាច្រើនជឿថាទាំងអស់ល្អតាមលក្ខណៈនិស្ស័យរបស់ខ្លួន ហើយហេតុដូច្នេះគេមាន

សុទិដ្ឋិនិយមចំពោះលទ្ធផលពីសកម្មភាពសិទ្ធិមនុស្ស ដូចជាការប្រកាសស្តីពីសិទ្ធិ មនុស្ស ។ គ្រីស្តបរិស័ទមិនត្រូវមានជំនឿខុសលើបែបនោះឡើយ។ ព្រះគម្ពីរបានបង្រៀនយ៉ាងច្បាស់ថាមនុស្សយើងមាននិស្ស័យបាប ហើយយើងមិនអាចមានសមត្ថភាពជួយសង្គ្រោះខ្លួនឯងបានឡើយ ក្រៅពីទទួលទណ្ឌកម្ម ដោយព្រោះអំពើបាបរបស់យើងនោះឡើយ ប៉ុន្តែអំពើបាបក៏មានអំណាចលើយើងដែរ ។[១០] ដំណោះស្រាយរបស់មនុស្សមិនអាចកែខៃបញ្ហារបស់ពិភពលោកនេះបានឡើយ ។ ប៉ុន្តែព្រះជាម្ចាស់បានធ្វើការនោះតាមរយៈព្រះយេស៊ូ ដើម្បីសង្គ្រោះយើងឲ្យរួចពីបាបរបស់យើង ។ ដំណោះស្រាយចំពោះបញ្ហានៅក្នុងលោកនេះគឺជាដំណឹងល្អ ។ នៅក្នុងដំណឹងល្អព្រះជាម្ចាស់មិនគ្រាន់តែអត់ទោសបាបឲ្យយើងប៉ុណ្ណោះទេ ប៉ុន្តែព្រះអង្គប្រទានជីវិតថ្មី ដើម្បីឲ្យយើងអាចស្តាប់បង្គាប់ដល់ព្រះអង្គទៀតផង ។ ការនេះផ្តល់នូវសេចក្តីសង្ឃឹមពិតសំរាប់សង្គមដ៏ប្រសើរ ។ យើងក៏នឹងត្រូវរង់ចាំទទួលពិភពលោកនៅថ្ងៃអនាគត នៅពេលដែលអ្វីទាំងអស់បានធ្វើឲ្យបានប្រសើរឡើង ។

## សរុបសេចក្តី

ប្រឈមមុខទៅនឹងការទទួលរងនូវការឈឺចាប់យ៉ាងច្រើននៅក្នុងលោកីយ៍នេះ គ្រីស្តបរិស័ទត្រូវការពារសិទ្ធិរបស់ពួកអ្នកក្រីក្រ អ្នកទន់ខ្សោយ និងអ្នកដែលត្រូវគេជិះជាន់សង្កត់សង្កិន ។ យើងត្រូវខំកែទម្រង់រដ្ឋាភិបាល ប្រព័ន្ធចាត់ចែងការងារផ្សេងៗ ប្រព័ន្ធច្បាប់ ក្រុមហ៊ុនជាដើម។ល។ ប្រយោជន៍ឲ្យមនុស្សទាំងអស់បានទទួលនូវភាពយុត្តិធម៌សមរម្យ ។

---

[១០] *សូមមើលរ៉ូម ៧:៧-២៤; អេភេសូរ ២:១-៣; យេរេមា ១៣:២៣; ១៧:៩ ។*

តែទោះជាយ៉ាងក៏ដោយ គ្រីស្ទបរិស័ទត្រូវប្រយ័ត្នផងដែរ ចំពោះការប្រើពាក្យ "សិទ្ធិមនុស្ស" ច្រើនហួសពេក ។ គ្រីស្ទបរិស័ទដែលធ្វើការជាមួយអង្គការមិនមែនជាគ្រីស្ទបរិស័ទ ត្រូវប្រុងប្រយ័ត្នដើម្បីពិនិត្យមើលនូវអ្វីដែលគេពួនោះ តើវាស្របទៅនឹងព្រះគម្ពីរឬអត់ ។

នៅពេលដែលយើងពិនិត្យមើលផ្សៀងផ្ទាត់ជាមួយព្រះគម្ពីរ ទើបយើងដឹងថាមានសង្កត់ធ្ងន់លើការទទួលខុសត្រូវរបស់មនុស្ស នៅចំពោះព្រះជាម្ចាស់ ។ យើងត្រូវប្រកាសអះអាងឲ្យលោកីយ៍នេះដឹងថា គេត្រូវតែទទួលខុសត្រូវចំពោះអ្វីដែលគេបានធ្វើចំពោះព្រះជាម្ចាស់ ដ្បិតការទទួលខុសត្រូវនោះ ព្រះអង្គបានផ្តល់គេនៅក្នុងទំនាក់ទំនងទាំងបីខាងលើដែលយើងបានលើកមកនិយាយរួចហើយនោះ ។ គ្មានអ្វីអាចលាក់កំបាំងពីព្រះអង្គបានឡើយ ព្រះអង្គទតឃើញគ្រប់ទាំងអស់នូវអ្វីដែលមាននៅក្នុងចិត្តរបស់យើង ។ លោកីយ៍ទាំងមូលនេះបានបះបោរទាស់ទទឹងនឹងព្រះជាម្ចាស់ ហេតុដូច្នេះហើយទើបលោកីយ៍នេះត្រូវស្ថិតនៅក្រោមការជំនុំជំរះរបស់ព្រះអង្គ ។ យើងមិនអាចមានសមត្ថភាពដោះស្រាយបញ្ហានេះ ដោយពឹងផ្អែកលើដំណោះស្រាយរបស់មនុស្ស ឬដោយពឹងផ្អែកលើសាសានារបស់មនុស្សនោះបានទេ ។ ប៉ុន្តែព្រះជាម្ចាស់ធ្វើការសង្គ្រោះយើងតាម រយៈព្រះយេស៊ូជាពិសេសតាមរយៈអ្វីដែលព្រះអង្គបានសម្រេចនៅកាលដែលព្រះអង្គសុគត និងមានព្រះជន្មរស់ឡើងវិញ ។ នៅក្នុងដំណឹងល្អព្រះជាម្ចាស់បានហៅមនុស្សឲ្យមកលន់តួនូវអំពើខុសឆ្គងដែលគេបានប្រព្រឹត្ត និងត្រូវព្រមទទួលជឿលើព្រះយេស៊ូ ។ ការនេះមិនគ្រាន់តែជួយឲ្យមានការសង្គ្រោះផ្ទាល់ខ្លួនឡើយ តែនាំឲ្យមានការផ្លាស់ប្រែសង្គមថែមទៀតផង ។